# ស្ថានីយ៍បញ្ចុះសពខាងលិចក្រុងអង្គរធំ

តាមរយៈការកំណាយបុរាណវិទ្យាជាច្រើននៅក្នុងតំបន់អង្គរ ដោយអ្នកស្រាវជ្រាវជាតិ និងអន្តរជាតិកន្លងមក បានរកឃើញស្ថានីយ៍បញ្ចុះសពចំនួនពីរ ដែលនៅពុំឆ្ងាយពីក្រុងអង្គរធំ ពោលគឺនៅបរិវេណតំបន់បារាយណ៍ខាងលិច។ ស្ថានីយ៍ទាំងនោះមានដូចជាព្រៃក្មេង និងកោះតាមាស ។

ព្រៃក្មេងគឺជាភូមិមួយដែលមានចម្ងាយ១៣គីឡូពីក្រុងអង្គរធំ និងនៅទីនោះមានប្រាសាទសម័យមុនអង្គរមួយដែលហៅថាប្រាសាទព្រៃក្មេង ។

នៅឆ្នាំ ២០១៤ តាមរយៈគម្រោង MAFKATA បានធ្វើកំណាយនៅខាងត្បូងប្រាសាទព្រៃក្មេង។ តាមរយៈលទ្ធផលនៃការកំណាយ បានបង្ហាញឱ្យឃើញស្រទាប់ដីនៅទីនោះមាន៤ស្រទាប់ ដែលស្រទាប់ទី១ រកឃើញមានកុលាលភាជន៍ផុយវត្ថុអំពីដែកជាច្រើនស្ថិតក្នុងសម័យអង្គរ និងឃើញមានប្រភេទឥដ្ឋដែលដូចនឹងឥដ្ឋប្រាសាទព្រៃក្មេងដែរ។[១] ស្រទាប់ទី២ និងទី៣ រកឃើញភាគច្រើនជាកុលាលភាជន៍ចិន និងឃើញមានភាជន៍ភ្នំគូលែន ស.វ.ទី១០[២] ហើយស្រទាប់ដីដែលសំខាន់ជាងគេនោះ គឺស្រទាប់ទី៤ ដែលរកឃើញផ្នូរចំនួន ១១[៣] ដោយផ្នូរទាំងនោះ ខ្លះជាផ្នូរតែឯង និងខ្លះទៀតផ្នូរជាក្រុម ព្រមទាំងមានវត្ថុសំណែនកប់ជាមួយ។[៤] តាមរយៈការសិក្សាលើធ្មេញនៃគ្រោងឆ្អឹងទាំងនោះបានបង្ហាញថា ជាមនុស្សក្មេង វ័យជំទង់ និងមនុស្សចាស់ ប្រុស ស្រី ក្នុងចំណោមនោះ មានគ្រោងឆ្អឹង២ប្រហែលជាក្មេងស្រី (អាយុ ១៣ទៅ១៥ឆ្នាំ), គ្រោងឆ្អឹង៣ ឬ ៤ប្រហែលជាមនុស្សប្រុស (មនុស្សវ័យកណ្ដាល ឬចាស់ជាង) នឹងគ្រោងឆ្អឹងក្មេងវ័យជំទង់២នាក់។[៥] តាមរយៈវត្ថុសិល្បៈដែលបានរកឃើញ និងការវិភាគកាបូន១៤ ផ្នូរទាំង១១នោះ គឺស្ថិតនៅចន្លោះពី២០០ទៅ៤០០ឆ្នាំ មុនគ.ស.[៦] ពោលគឺស្ថិតនៅក្នុងយុគដែក។

---

[១] Dougald O'REILLY, Louise SHEWAN, Kate DOMETT and An SOPHEAP 2020:36

[២] *ibid* :38

[៣] *ibid*

[៤] ដូចជា កុលាលភាជន៍ គ្រឿងអលង្ការធ្វើអំពីសំរិទ្ធ និងដែក ។

[៥] Pottier 2003

[៦] Dougald O'REILLY, Louise SHEWAN, Kate DOMETT and An SOPHEAP 2020:39-53

អត្ថបទដោយ៖ អេង តុលា




រូបលេខ១៖ ផែនទីបង្ហាញពីទីតាំងស្ថានីយ៍ព្រៃក្មេង
ប្រភព៖ Google Earth



រូបលេខ២-៣៖ ផ្នូរដែលមានគ្រោងឆ្អឹងនឹងវត្ថុសំណែន
ប្រភព៖ MAFKATA



តាមរយៈការស្រាវជ្រាវផ្នែកបុរាណវិទ្យាមួយធ្វើឡើងរវាងសាលាបារាំងចុងបូព៌ា និងអាជ្ញាធរអប្សរាក្នុងឆ្នាំ២០០៤-២០០៥ បានកំណាយនៅស្ថានីយ៍មួយដែលអ្នកស្រុកហៅថាកោះតាមាសដែលស្ថិតនៅក្នុងបារាយណ៍ខាងលិច និងនៅខាងលិចប្រាសាទមេបុណ្យ។

អត្ថបទដោយ៖ អេង តុលា

ជាលទ្ធផលនៃការកំណាយនោះ បានរកឃើញផ្នូរចំនួន២៧[៧]ដែលមានគ្រោងឆ្អឹងទាំងមូល រួមជាមួយវត្ថុសំណែនផ្សេងៗ និងឆ្អឹងសត្វជាច្រើនទៀតដែលបានរកឃើញ។ ចំពោះផ្នូរទាំង២៧នោះ មាន១៩ដែលមានគ្រោងឆ្អឹងមនុស្សទាំងមូល និង១២ទៀតពុំមានគ្រោងឆ្អឹងពេញលេញនោះទេ។[៨] តាមរយៈគ្រោងឆ្អឹង វត្ថុសិល្បៈ និងសំណល់ឆ្អឹងសត្វដែលបានរកឃើញនៅស្ថានីយ៍នេះ បានបង្ហាញថាស្ថានីយ៍នេះមានការតាំងទីរស់នៅ និងជាកន្លែងកប់សពផងដែរ ដែលស្ថិតនៅក្នុងយុគសំរិទ្ធ។[៩] បញ្ជាក់ដែរថា ឆ្អឹងសត្វដែលបានរកឃើញទាំងនោះពុំមែនមានន័យថាជាសត្វដែលរស់នៅជុំវិញនៃស្ថានីយ៍នេះទេ ប្រហែលជាសំណល់ដែលមនុស្សសម័យនោះបរិភោគ ឬយកមកកែច្នៃធ្វើជាឧបករណ៍ប្រើប្រាស់ផ្សេងៗទៀត។[១០] បច្ចុប្បន្នវត្ថុសិល្បៈ ក៏ដូចជាគ្រោងឆ្អឹងដែលបានរកឃើញទាំងនោះ បានដាក់តាំងបង្ហាញនៅក្នុងសារមន្ទីរព្រះសីហនុរាជក្នុងខេត្តសៀមរាប។

ការរកឃើញពីស្ថានីយ៍បញ្ចុះសពទាំងពីរនេះ គឺបានផ្តល់ទិន្នន័យប្រវត្តិសាស្ត្រអំពីការតាំងទីរស់នៅរបស់មនុស្សនៅតំបន់ខាងលិចក្រុងអង្គរ តាំងពីសម័យបុរេប្រវត្តិសាស្ត្រមកម្ល៉េះ និងនៅសម័យមុនអង្គរ និងអង្គរ មនុស្សបន្តកសាងសំណង់ស្ថាបត្យកម្មសាសនានៅលើទីតាំងចាស់ផងដែរ។

ចំពោះស្ថានីយ៍បញ្ចុះសពសម័យអង្គរដែលរកឃើញនៅក្នុងតំបន់អង្គរវិញ គឺពុំសូវមានទិន្នន័យនោះទេ ប៉ុន្តែដូចដែលខ្ញុំធ្លាប់បានបង្ហាញ ពីអត្ថបទមុនមកហើយ អំពីការកំណាយស្រះស្រង់ឆ្នាំ ១៩៦៤ ដែលបានបង្ហាញអំពីស្រទាប់ទី២នៃស្រះស្រង់ជាកន្លែងដែលមនុស្សសម័យអង្គរ យកទីតាំងនេះធ្វើជាកន្លែងបញ្ចុះសព ហើយនេះគឺជាការរកឃើញដំបូង និងក៏ជាឧទាហរណ៍តែមួយអំពីស្ថានីយ៍បញ្ចុះសពសម័យអង្គរដែលបានរកឃើញនៅក្នុងតំបន់អង្គរ ហើយការរកឃើញនេះគឺតាំងពីសម័យបារាំង ប៉ុន្តែតាមរយៈការកំណាយស្រាវជ្រាវក្រោយៗមកទៀតបានបង្ហាញស្ថានីយ៍ ពីរផ្សេងទៀតប្រហែលជា

---

[៧] សូមមើល M.A. Frelat · C. Souday The Bronze Age necropolis of Koh Ta Meas: insights into the health of the earliest inhabitants of the Angkor region, 2015

[៨] *ibid:* 2

[៩] *ibid:* 12

[១០] *ibid*

អត្ថបទដោយ៖ អេង តុលា

កន្លែងបញ្ចុះសពសម័យអង្គរមួយ គឺនៅប្រាសាទទ្រមូង[១១] ដែលប្រាសាទរបស់មន្ទីរពេទ្យ នឹងមួយទៀតនៅពើងត្បាល់លើភ្នំគូលែន។[១២]




រូបលេខ២៤៖ ផែនទីបង្ហាញពីទីតាំងកោះតាមាស ដែលនៅក្បែរស្ថានីយ៍ព្រៃក្មេងដែរ
ប្រភព៖ Google Earth



រូបលេខ២៥៖ ការដាក់តាំងវត្ថុសិល្បៈ និងគ្រោងឆ្អឹងដែលរកឃើញនៅសារ
មន្ទីរព្រះសីហនុរាជក្នុងខេត្តសៀមរាប

[១១] សូមមើល Christophe Pottier & Rethy Kieth Chhem, A la découverte d'un hôpital angkorien: résultats préliminaire d'une campagne archéologique au Prasat Tromoung.

[១២] សូមមើល Jean Baptiste Chevance, Poeng Tbal et Poeng Eisei, ermitages angkoriens méconnus du Phnom Kulen.

អត្ថបទដោយ៖ អេង តុលា




រូបលេខ២៦៖ ផ្នូរសពដែលមានគ្រោងឆ្អឹងមនុស្ស សត្វ និងវត្ថុសំណែន
ប្រភព៖ Christophe Pottier




រូបលេខ២៧៖ ផ្នូរសពដែលមានគ្រោងឆ្អឹងមនុស្ស សត្វ និងវត្ថុសំណែន
ប្រភព៖ Christophe Pottier

អត្ថបទដោយ៖ អេង តុលា

## ឯកសារយោង


Dougald O’REILLY, Louise SHEWAN, Kate DOMETT, and An SOPHEAP

2020 ‘’ *Revisiting Prei Khmeng: The Excavation of an Iron Age Settlement and Cemetery in Cambodia*’’

Pottier Christophe, Pierre Baty, Fabrice Demeter and Alexandre Guerin

2003 ‘’*Mission Archéologique Franco-Khmère sur l’Aménagement du Territoire Angkorien (MAFKATA):Campagne 2003*’’ Rapport [Franco-Khmer Archaeological Mission on the Angkorian Territory(MAFKATA: 2003 Campaign Report)], ed. C. Pottier.Siem Reap : Ecole française d’Extrême-Orient

2005 ‘’ *Rapport de synthèse sur les fouilles à Koh TaMéas, dans le baray occidenta’’l*. In: Pottier C, et al (ed) Mission Archéologique Franco-Khmère sur l’Aménagement du Territoire Angkorien (MAFKATA). Rapport sur la campagne 2006. APSARA-MAE-EFEO, SiemReap, pp 61-85

Christophe Pottier & Rethy Kieth Chhem

2006 *A la découverte d’un hôpital angkorien : résultats préliminaires d’une campagne archéologique au Prasat Tromoung*, Udaya

Frelat MA, Souday C, Buchet N, Demeter F

2005, *Etude anthropologique d’une nécropole – Rapport préliminaire*. In: PottierC, et al (ed) Mission Archéologique Franco-Khmère sur l’Aménagement du Territoire Angkorien (MAFKATA). Rapport sur la campagne 2006. APSARA-MAE-EFEO, Siem- Reap, pp 88–118

Jean Baptiste Chevance

2010 *Poeng Tbal et Poeng Eisei, ermitages angkoriens méconnus du Phnom Kulen.*


KHMER CIVILIZATION

អត្ថបទដោយ៖ អេង តុលា